# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ ១២២.រប-៩៤

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការខេត្ត ក្រុង ទូទាំងប្រទេស**

*សូមជ្រាប។*

**កម្មវត្ថុ:** សេចក្ដីណែនាំអំពីប្រាក់ប្រដាប់ក្ដីរឿងរដ្ឋប្បវេណី ។

ខ្ញុំសូមជម្រាបអស់ លោកថា ក្រឹត្យ លេខ ០៧.ក ចុះថ្ងៃទី០៨-០២-៩៣ ចូលជាធរមាន នៅថ្ងៃទី០៨-០២-៩៣ តម្រូវអោយភាគីដើមចោទក្នុងរឿងរដ្ឋប្បវេណីបង់ប្រាក់ប្រដាប់ក្ដីដូចមានចែងក្នុងច្បាប់ស្រាប់ ។ ចំពោះបញ្ហានេះ ក្រសួងបានបើកវគ្គបំពាក់បំប៉ន ដល់ក្រឡាបញ្ជីគ្រប់ខេត្ត-ក្រុង ដែលមានភារកិច្ចបំពេញកិច្ចការនេះរួចហើយ ។ ប៉ុន្តែខ្ញុំនៅតែសង្កេតឃើញមានតុលាការ ខេត្ត-ក្រុង ខ្លះពុំបានអនុវត្តតាមក្រឹត្យខាងលើនេះនៅឡើយ សូម្បីតែប្រាក់ពន្ធចុះបញ្ជីក្ដី ពន្ធហ្នឹង និងរង្វាន់ក្រឡាបញ្ជី ក៏ពុំបានគិតគូរដែរ ដែលជាហេតុធ្វើអោយបង់ខាតប្រាក់ថវិកាជាតិច្រើន និងប៉ះពាល់ដល់នីតិវិធី ។

ខ្ញុំសូមបញ្ជាក់ថា រឿងវិវាទរដ្ឋប្បវេណី ដែលបានជំនុំជម្រះក្រោយថ្ងៃទី០៨-០២-៩៣ ដែលជាថ្ងៃចូលជាធរមានបញ្ញត្តិ ហើយពុំទាន់បង់ប្រាក់នេះ ត្រូវតុលាការខេត្ត ក្រុង អញ្ជើញភាគីដែលឈ្នះក្ដីអោយបង់ប្រាក់ប្រដាប់ក្ដីដូចបានពោលខាងលើនេះព្រមទាំងពន្ធសមាមាត្រផង បើកាលណាសាលក្រមនោះចូលជាស្ថាពរហើយ ។

រឿងបង់ប្រាក់ប្រដាប់ក្ដីក្នុងពេលនេះចាត់ទុកជាការពិសេសពីព្រោះតម្រូវឲ្យបង់ក្រោយការជំនុំជម្រះ ដូច្នេះរបៀបចាត់ការមានដូចតទៅៈ

មុនដំបូងត្រូវចេញបង្កាន់ដៃតាមទឹកប្រាក់ដែលត្រូវបង់ និងចុះក្នុងសៀវភៅហិបប្រាក់រួចចុះក្នុងសៀវភៅនាំយកប្រាក់ទៅដាក់ឃ្លាំងទាំងពន្ធចុះបញ្ជីក្ដី ទាំងពន្ធហ្នឹងព្រមទាំងពន្ធសមាមាត្រផងបើប្រសិនជាមាន ហើយចុះក្នុងសៀវភៅចំណាយប្រាក់ប្រដាប់ក្ដីដូចប្រក្រតី តែកុំភ្លេចចុះលេខថ្ងៃ-ខែ-ឆ្នាំ សាលក្រមក្នុងសៀវភៅនោះផង ។ប្រាក់នេះត្រូវបង់ចូលឃ្លាំងទាំងអស់តែម្ដងក្នុងខែចេញបង្កាន់ដៃនោះលើកលែងតែរង្វាន់ក្រឡាបញ្ជីដែលត្រូវបានជាប្រយោជន៍ដល់ក្រឡាបញ្ជីនាយកដែលគ្រប់គ្រងហិបប្រាក់ ។

ម្យ៉ាងទៀតរឿងវិវាទរដ្ឋប្បវេណី ដែលតុលាការជំនុំជម្រះក្រោយថ្ងៃទី០៨-០២-៩៣ ហើយដែលមានភាគីម្ខាងឧទ្ធរណ៍ ហើយតុលាការខេត្ត-ក្រុង ពុំបានអនុវត្តតាមក្រឹត្យនេះ ក្រសួងងនឹងបញ្ជូនត្រឡប់ទៅវិញ អោយបង់ប្រាក់ប្រដាប់ក្ដីសិន ទើបសាលាឧទ្ធរណ៍យករឿងនោះមកជំនុំជម្រះបាន ។

បើអនុវត្តទៅហើយជួបប្រទះការលំបាក សូមអញ្ជើញមកទាក់ទងនឹងនាយកដ្ឋានបច្ចេកទេសនៃក្រសួងយុត្តិធម៌ ដើម្បីពិភាក្សារកការដោះស្រាយសមស្រប ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្នួន**

<u>ចម្លងជូន</u>

-ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង
-តុលាការកំពូលនិងមហាអយ្យការ
-សាលាឧទ្ធរណ៍និងមហាអយ្យការ
-ដើម្បីជ្រាប និងតាមដាន